ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៦៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការប្រែក្លាយពីទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ទៅជាទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការស្ថិតនៅក្រៅក្របខណ្ឌដើមចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមស្នើសុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល

គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់ពីការប្រែក្លាយទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ទៅជា“ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ” ដែលសរសេរជាអក្សរកាត់ថា **ទ.ជ.ប.**។

**ទ.ជ.ប.** ស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ **ទ.ជ.ប.** មានឋានៈស្មើអគ្គនាយកដ្ឋាន។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការបញ្ជាក់លើការស្នើសុំទូទាត់ចំណាយសេវាសុខាភិបាលនៃមូលនិធិសមធម៌សុខាភិបាល និងសេវាវេជ្ជសាស្ត្ររបស់មូលដ្ឋានសុខាភិបាលនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ។

**មាត្រា៣.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើប្រាស់ក្នុងអនុក្រឹត្យនេះ មាននិយមន័យ ដូចខាងក្រោម÷

- **សេវាវេជ្ជសាស្ត្រ** សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យនៃមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គម។
- **ភាគីផ្តល់សេវា** សំដៅដល់មូលដ្ឋានសុខាភិបាលសាធារណៈ និងមូលដ្ឋានសុខាភិបាលឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គម។
- **ប្រព័ន្ធវាយតម្លៃបច្ចេកវិទ្យាសុខាភិបាល (HTA)** សំដៅដល់ការសិក្សាវាយតម្លៃជាប្រព័ន្ធលើប្រសិទ្ធភាពចំណាយ, សុវត្ថិភាពនៃការព្យាបាល, និងផលប៉ះពាល់នៃការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការព្យាបាល ដោយផ្តល់អាទិភាពលើទិដ្ឋភាពវេជ្ជសាស្ត្រ, សង្គម, សីលធម៌ និងសេដ្ឋកិច្ច។ គោលបំណងចម្បងរបស់ HTA គឺដើម្បីផ្តល់ធាតុចូលជូនថ្នាក់ដឹកនាំសម្រាប់ធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការថែទាំសុខភាព ដែលរួមមានជាអាទិ៍ការគ្របដណ្តប់សេវាថែទាំសុខភាព, ការទូទាត់, ការកំណត់ថ្លៃទូទាត់, ការកំណត់គោលការណ៍ណែនាំនៃការព្យាបាលជំងឺ, ការត្រួតពិនិត្យឧបករណ៍វេជ្ជសាស្ត្រ។
- **គោលនយោបាយទិញដោយយុទ្ធសាស្ត្រ (Strategic Purchasing)** សំដៅដល់យុទ្ធសាស្ត្រហិរញ្ញប្បទានសុខាភិបាលដែលផ្តល់មូលនិធិដល់អ្នកផ្តល់សេវា ដោយផ្សារភ្ជាប់នូវលក្ខខណ្ឌគុណភាពនៃការផ្តល់សេវា និងការឆ្លើយតបនឹងតម្រូវការសេវាថែទាំសុខភាពរបស់អ្នកជំងឺពីសំណាក់អ្នកផ្តល់សេវា។

# ជំពូកទី ២
# បេសកកម្ម តួនាទី និងភារកិច្ច

**មាត្រា៤.-**

**ទ.ជ.ប.** ជាអង្គភាពរដ្ឋបាល និងបច្ចេកទេសផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាជាតិគាំពារសង្គមក្នុងការបញ្ជាក់លើរាល់ការស្នើសុំទូទាត់ចំណាយ (១) សេវាសុខាភិបាលនៃមូលនិធិសមធម៌សុខាភិបាល និង (២) សេវាវេជ្ជសាស្ត្រនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ។

**មាត្រា៥.-**

**ទ.ជ.ប.** មានតួនាទី និងភារកិច្ច ដូចតទៅ÷

- ពិនិត្យ និងបញ្ជាក់ការស្នើសុំរបស់ភាគីផ្តល់សេវាក្នុងការទូទាត់ថ្លៃសេវាវេជ្ជសាស្ត្រ
- តាមដាន ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់ចំណាយនៃមូលនិធិសមធម៌សុខាភិបាល និងវាយតម្លៃផ្ទៀងផ្ទាត់គុណភាពសេវានៃមូលនិធិលើកកម្ពស់គុណភាពសេវាសុខាភិបាល និងគម្រោងលើកកម្ពស់សមធម៌ និងគុណភាពសេវាសុខាភិបាល
- សហការជាមួយក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃបេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) ដើម្បីតាមដាន និងវាយតម្លៃគុណភាពសេវាសុខាភិបាលនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារ អនុលោមតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ រៀបចំ និងដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធនឹងយន្តការទូទាត់ចំណាយសេវាព្យាបាលវេជ្ជសាស្ត្រ
- ចូលរួមបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃបច្ចេកវិទ្យាសុខាភិបាល
- ផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិគាំពារសង្គមលើការងារគោលនយោបាយទិញដោយយុទ្ធសាស្ត្រ ការកំណត់កញ្ចប់គាំពារកាលិក និយាមគុណភាពសេវាសុខាភិបាល និងតារាងថ្លៃសេវាសុខភាព
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

# ជំពូកទី ៣
# រចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ ទ.ជ.ប.

## ផ្នែកទី១
## រចនាសម្ព័ន្ធ

**មាត្រា៦.-**

**ទ.ជ.ប.** មានរចនាសម្ព័ន្ធដូចខាងក្រោម÷

- នាយកដ្ឋានបញ្ជាក់ចំណាយ



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

- នាយកដ្ឋានគោលនយោបាយ
- នាយកដ្ឋានគ្រប់គ្រងទិន្នន័យ និងបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានកិច្ចការទូទៅ។

**មាត្រា៧**.-

**ទ.ជ.ប.** ដឹកនាំដោយអគ្គនាយក ១ (មួយ) រូប និងមានអគ្គនាយករងមួយចំនួន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ អគ្គនាយកត្រូវតែងតាំង និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។ អគ្គនាយករងត្រូវតែងតាំង និងបញ្ចប់មុខតំណែងដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

នាយកដ្ឋាននីមួយៗនៃ **ទ.ជ.ប.** ដឹកនាំដោយប្រធាន ១ (មួយ) រូប និងមានអនុប្រធានមួយចំនួន អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខ របស់ **ទ.ជ.ប.** ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**ទ.ជ.ប.** មាននិមិត្តសញ្ញា និងត្រា ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា៨**.-

នាយកដ្ឋានបញ្ជាក់ចំណាយមានភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់លើការស្នើសុំទូទាត់ចំណាយសេវាសុខាភិបាលនៃមូលនិធិសមធម៌សុខាភិបាល និងសេវាវេជ្ជសាស្ត្ររបស់មូលដ្ឋានសុខាភិបាលនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ
- អនុវត្តដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់លើការស្នើសុំចំណាយក្នុងការទូទាត់ថ្លៃសេវា
- វាយតម្លៃ ផ្ទៀងផ្ទាត់គុណភាពសេវា ក្នុងក្របខណ្ឌនៃមូលនិធិលើកកម្ពស់គុណភាពសេវាសុខាភិបាល និងគម្រោងលើកកម្ពស់សមធម៌ និងគុណភាពសេវាសុខាភិបាល
- អនុវត្តការងារផ្សេងៗទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំនៃ **ទ.ជ.ប.**។

**មាត្រា៩**.-

នាយកដ្ឋានគោលនយោបាយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងវែងរបស់ **ទ.ជ.ប.**
- ចូលរួមកំណត់កញ្ចប់អត្ថប្រយោជន៍ និងយន្តការទូទាត់/បើកផ្តល់ នៃមូលនិធិសមធម៌សេវាសុខាភិបាល និងមូលនិធិលើកកម្ពស់គុណភាពសេវាសុខាភិបាល
- ផ្សព្វផ្សាយសេចក្តីសម្រេចរបស់ **ទ.ជ.ប.** និងគោលនយោបាយពាក់ព័ន្ធនានា

- ផ្សព្វផ្សាយជូនសាធារណជន អំពីលក្ខណៈវិនិច្ឆ័យ សិទ្ធិ នីតិវិធី និងកញ្ចប់អត្ថប្រយោជន៍ក្នុងការទទួលសេវាសុខាភិបាលនៃមូលនិធិសមធម៌សេវាសុខាភិបាល ដោយសហការជាមួយក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បណ្តុះបណ្តាល និងសម្របសម្រួលការគ្រប់គ្រងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវអំពីសេវាសុខាភិបាល ដើម្បីជាធាតុចូលនៃការសម្រេចចិត្តសម្រាប់ការរៀបចំយុទ្ធសាស្ត្រ និងនីតិវិធីពាក់ព័ន្ធនឹងយន្តការគ្រប់គ្រងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ មូលនិធិសមធម៌សុខាភិបាល និងមូលនិធិលើកកម្ពស់គុណភាពសេវាសុខាភិបាល
- ចូលរួមបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃបច្ចេកវិទ្យាសុខាភិបាល
- ចូលរួមរៀបចំគោលនយោបាយទិញដោយយុទ្ធសាស្ត្រ កំណត់កញ្ចប់តាវកាលិក និយាមគុណភាពសេវាសុខាភិបាល និងតារាងថ្លៃសេវាសុខភាព
- អនុវត្តការងារផ្សេងៗទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំនៃ **ទ.ជ.ប.**។

**មាត្រា១០.-**

នាយកដ្ឋានគ្រប់គ្រងទិន្នន័យ និងបច្ចេកវិទ្យាព័ត៌មាន មានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាពិសេសប្រព័ន្ធដែលពាក់ព័ន្ធនឹងការកត់ត្រា និងការគ្រប់គ្រងទិន្នន័យអ្នកជំងឺ (PMRS) ដែលទទួលការគាំពារសង្គម
- អភិវឌ្ឍ ថែទាំ និងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដើម្បីធានានូវដំណើរការរលូននៃថ្នាលឌីជីថល មូលដ្ឋានទិន្នន័យ និងសុវត្ថិភាពទិន្នន័យ
- ធានាគុណភាពទិន្នន័យ និងចូលរួមសហការក្នុងក្របខណ្ឌនៃការផ្លាស់ប្តូរទិន្នន័យពាក់ព័ន្ធនានា
- អនុវត្តការងារផ្សេងៗទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំនៃ **ទ.ជ.ប.**។

**មាត្រា១១.-**

នាយកដ្ឋានកិច្ចការទូទៅ មានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង និងគ្រប់គ្រងការងារផ្នែករដ្ឋបាល, បុគ្គលិក និងហិរញ្ញវត្ថុ
- រៀបចំផែនការសកម្មភាពការងារ និងគម្រោងថវិការបស់ **ទ.ជ.ប.** ដោយគោរពតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន
- អនុវត្តថវិកា និងរៀបចំរបាយការណ៍អនុវត្តចំណូល-ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ **ទ.ជ.ប.** ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- អនុវត្តការងារផ្សេងៗទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំនៃ **ទ.ជ.ប.**។



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**មាត្រា១២**.-

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យក្រោមចំណុះនាយកដ្ឋាននីមួយៗនៃ **ទ.ជ.ប.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ផ្នែកទី២

## មន្ត្រី និងបុគ្គលិក

**មាត្រា១៣**.-

**ទ.ជ.ប.** អាចជ្រើសរើសមន្ត្រីរាជការមុខងារសាធារណៈ ពីក្រសួង-ស្ថាប័ននានា និងពីក្នុងចំណោមសិស្សនិស្សិតមកបម្រើការងារនៅ **ទ.ជ.ប.** ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមនីតិវិធីជាធរមាន។

**មាត្រា១៤**.-

**ទ.ជ.ប.** អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាឱ្យមកបម្រើការងារ និងអាចជ្រើសរើសទីប្រឹក្សាជាអ្នកជំនាញការជាតិ ឬអន្តរជាតិ ដោយមានការឯកភាពពីប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

**មាត្រា១៥**.-

បុព្វលាភ និងប្រាក់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំ និងមន្ត្រីដែលបម្រើការងារនៅ **ទ.ជ.ប.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ផ្នែកទី៣

## ថវិកា

**មាត្រា១៦**.-

**ទ.ជ.ប.** មានកញ្ចប់ថវិកាដោយឡែកសម្រាប់គាំទ្រដល់កិច្ចដំណើរការ។ ថវិការបស់ **ទ.ជ.ប.** អាចមានប្រភពមកពី÷

១. ថវិការដ្ឋដែលស្ថិតនៅក្រោមកញ្ចប់ថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង

២. ប្រភពស្របច្បាប់ផ្សេងៗទៀត។

ថវិការបស់ **ទ.ជ.ប.** ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការស្នើសុំរបស់អគ្គនាយក តាមរយៈប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ផ្នែកទី៤
## ការត្រួតពិនិត្យ

**មាត្រា១៧.-**

**ទ.ជ.ប.** ត្រូវស្ថិតក្រោមការធ្វើអធិការកិច្ច និងសវនកម្ម ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤
## បែបបទ និងនីតិវិធីនៃការបញ្ជាក់ចំណាយ

**មាត្រា១៨.-**

ប្រតិបត្តិករគ្រប់គ្រងមូលនិធិសមធម៌សុខាភិបាល និងស្ថាប័នប្រតិបត្តិករសន្តិសុខសង្គមអាចទូទាត់លើការស្នើសុំចំណាយ ដែលបានបញ្ជាក់ពី **ទ.ជ.ប.** ប៉ុណ្ណោះ។

សេវាព្យាបាលវេជ្ជសាស្ត្រ ជាកម្មវត្ថុនៃការស្នើសុំចំណាយដែលត្រូវបញ្ជាក់ដោយ **ទ.ជ.ប.** អាចរងការត្រួតពិនិត្យដល់ទីកន្លែងតាមការចាំបាច់។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបញ្ជាក់ចំណាយ និងការត្រួតពិនិត្យដល់ទីកន្លែងលើសេវាព្យាបាលវេជ្ជសាស្ត្ររបស់មូលដ្ឋានសុខាភិបាលនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារក្រោមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទទួលបន្ទុកវិស័យសន្តិសុខសង្គម។

**មាត្រា១៩.-**

ការបញ្ជាក់លើការស្នើសុំទូទាត់ចំណាយសេវាវេជ្ជសាស្ត្ររបស់មូលដ្ឋានសុខាភិបាល នៃរបបសន្តិសុខសង្គមត្រូវចាប់ផ្តើមអនុវត្តដោយការបញ្ជាក់លើការស្នើសុំសុំទូទាត់ចំណាយសេវាវេជ្ជសាស្ត្រ នៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព។

កាលបរិច្ឆេទ សម្រាប់ការចាប់ផ្តើមអនុវត្តការបញ្ជាក់លើការស្នើសុំទូទាត់ចំណាយសេវាវេជ្ជសាស្ត្រនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា២០.-**

ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល (**ទ.ប.ច.ស.**) ត្រូវបន្តដំណើរការរហូតដល់ **ទ.ជ.ប.** ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការជាស្ថាពរ។



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

**មាត្រា២១.-**

មន្ត្រីរាជការដែលបម្រើការងារនៅ **ទ.ប.ច.ស.** បច្ចុប្បន្ន ត្រូវផ្ទេរក្របខណ្ឌពីក្រសួងសុខាភិបាល មកក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែសាមីខ្លួនមានការស្នើសុំស្ថិតនៅក្របខណ្ឌដើម។

មន្ត្រីរាជការដែលផ្ទេរភារកិច្ចឱ្យមកបម្រើការងារនៅ **ទ.ជ.ប.** ដោយដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម ត្រូវផ្អាកបៀវត្សពីក្រសួងដើម ហើយផ្ទេរបៀវត្សទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងមុខតំណែង ដោយទទួលបៀវត្សទៅតាមប្រភេទបៀវត្សចុងក្រោយ។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខណ្ឌដើមនេះ ត្រូវបានគិតអតីតភាពសម្រាប់ការឡើងថ្នាក់ ការឡើងឋានន្តរស័ក្តិ និងគិតអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍នៅអង្គភាពដើម។

ក្រោយពេលបញ្ចប់ពីមុខតំណែងក្នុង **ទ.ជ.ប.** មន្ត្រីសាមីត្រូវដាក់ពាក្យសុំចូលបម្រើការងារក្នុងក្របខណ្ឌដើមវិញ ដោយផ្តល់ជូនជាស្វ័យប្រវត្តិនូវឋានន្តរស័ក្តិ និងថ្នាក់អនុលោមតាមកថាខណ្ឌខាងលើ។ សាមីមន្ត្រីនឹងទទួលបានសិទ្ធិជាអាទិភាពក្នុងការតែងតាំងមុខតំណែងដើម ឬមុខតំណែងទំនេរប្រហាក់ប្រហែលនឹងមុខតំណែងដើម ផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង និងការសម្រេចរបស់ប្រធានស្ថាប័ន។

**មាត្រា២២.-**

ត្រូវបានបង្កើតគណៈកម្មការមួយឈ្មោះ "គណៈកម្មការបញ្ជីសារពើភណ្ឌ" ដើម្បីរៀបចំជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ **ទ.ប.ច.ស.** អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

រាល់ទ្រព្យសកម្មដែលជាចលនទ្រព្យ និងអចលនទ្រព្យរបស់ **ទ.ប.ច.ស.** ត្រូវផ្ទេរមក **ទ.ជ.ប.** ដោយផ្លាស់ប្តូរការចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋពីក្រសួងសុខាភិបាលមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

**មាត្រា២៣.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយ ដែលស្ថិតនៅក្រោមអានុភាពនៃអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការបង្កើតទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ជាគ្រឹះស្ថានសាធារណៈ ត្រូវបន្តអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិអនុក្រឹត្យនេះ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា២៤.-**

អនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការបង្កើតទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



តេឡេក្រាម ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ...១៦៣ អនក្រ.បក... ចុះថ្ងៃទី...១៧...... ខែ...កក្កដា.. ឆ្នាំ២០២៣
ស្តីពីការប្រែក្លាយពីទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាលទៅជាទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ

## អង្គការលេខទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ



**ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ...១៦៣...អនក្រ.បក..... ចុះថ្ងៃទី...១៧...... ខែ...កក្កដា.. ឆ្នាំ២០២៣**

**ស្ដីពីការប្រែក្លាយពីទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាលទៅជាទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ**

## និមិត្តសញ្ញារបស់ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ

**អត្ថន័យ÷**

- **រូបដំបូល** តំណាងឱ្យប្រព័ន្ធដែលផ្ដល់ការគាំពារប្រជាជនឱ្យរួចផុតពីភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាពសង្គម ដែលការរចនាត្រូវបានធ្វើឡើងដោយយោងទៅតាមក្បាច់ចម្លាក់លើប្រាសាទខ្មែរក្នុងតំបន់អង្គរ។
- **រូបមនុស្សក្រោមដំបូល** តំណាងឱ្យប្រជាជនកម្ពុជាក្នុងវ័យ និងភេទផ្សេងៗគ្នា ដែលទទួលបានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល និងជាអ្នកទទួលផលពីប្រព័ន្ធគាំពារសង្គមនៅគ្រប់ដំណាក់កាលនៃវដ្តជីវិត និងគ្រប់ស្រទាប់វណ្ណៈ។
- **ពណ៌បៃតង** តំណាងឱ្យការអភិវឌ្ឍ និងការរីកចម្រើនប្រកបដោយចីរភាពរបស់សង្គមជាតិកម្ពុជាដែលជាមូលដ្ឋានគ្រឹះផង និងជាផ្លែផ្កាផងនៃការអនុវត្តគោលនយោបាយជាតិគាំពារសង្គម។
- **ពណ៌ខៀវ** តំណាងឱ្យភាពក្លាហាន ទំនុកចិត្ត និងភាពទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តគោលនយោបាយជាតិគាំពារសង្គម។
- **សញ្ញាត្រឹមត្រូវមួយគូពណ៌ខៀវ** តំណាងឱ្យការបញ្ជាក់ពីការទទួលស្គាល់ពីភាពត្រឹមត្រូវ។

តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

# ត្រារបស់ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ